ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*******

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ ១៤៤

ចុះថ្ងៃទី២០ខែឧសភាឆ្នាំ១៩៩៩

សាលដីកា

លេខ : ២១៦

ចុះថ្ងៃទី១៤ខែធ្នូឆ្នាំ១៩៩៩

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ខិត មុន្នី ប្រធាន

២- លោក ប៉ែន ស៊ុន ចៅក្រម

៣- លោក ឃៀល មួន ចៅក្រម

៤- លោក ជីវ កេង ចៅក្រម

៥- លោក ឈឹម ស៊ីផល ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

អ្នកស្រី អ៊ួង ឡានី

តំណាងមហាអយ្យការ

លោក ជួន ស៊ុនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៨៦ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៨០ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ថូ ណាណា ភេទ ប្រុស អាយុ ៨៦ឆ្នាំ ជាតិខ្មែរ មុខរបរ ពាណិជ្ជករ ទីលំនៅផ្ទះលេខ ២០១$BE_1$ ផ្លូវម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

មានមេធាវី លោក សោម ចន្ទនីណា ជាតំណាង

និងចុងបណ្តឹងសាទុក្ខឈ្មោះសេង យៀន ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅផ្ទះលេខ ៤០២$E_0$ សង្កាត់មិត្តភាព ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ឈុន សេង ( ស ) ម្តាយឈ្មោះ ហង្ស ឡាយ ( រ ) ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងសុំឱ្យគោរពកិច្ចសន្យា និង ទារសំណងបង់ខាត

បានឃើញបណ្តឹងសាទុក្ខលេខ៨៦ ចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ១៩៩៩ របស់លោក ថូ ណាណា បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ៨៦ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៤៤ ចុះថ្ងៃទី២០ខែឧសភាឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៣_៥_៩៨ របស់ឈ្មោះសេង ឃៀន ជាដើមចោទថា : ខ្លួនសុំប្តឹងពីឈ្មោះ ម៉ូ ណាណា ដែលមិនគោរពកិច្ចសន្យារវាងក្រុមហ៊ុន ស្តារប៊ីយូធី STAR BEAUTY និងហាងទឹកអប់ ៤០២ ស្ស៊ូលី_ម៉ាដាម JOLIE MADAME ដោយទាមទារការបង់ខាតចំនួន ៣៣០៣៣ $US និងប្រាក់ជម្ងឺចិត្តចំនួន ៨០០០SUS ដោយសំអាងហេតុថា ឈ្មោះ ម៉ូ ណាណា ដែលជាម្ចាស់ភាគហ៊ុន នៃក្រុមហ៊ុន STAR BEAUTY រួមមានឈ្មោះ តុង ហ្វួត , ម៉ូ ណាណា និងឈ្មោះ ជា លឹម បាននាំមុខទំនិញម៉ាក្ស ARNAUD ចំនួន១២ប្រភេទផ្ទាល់មុខពីប្រទេសបារាំង ដោយចុះកិច្ចសន្យាឱ្យហាងទឹកអប់ ៤០២ JOLIE MADAME លក់ផ្តាច់នៅក្នុងស្រុកខ្មែរ ។ ក្រោយពីខ្លួនបានរៀបចំផ្សាយពាណិជ្ជកម្ម និង ធ្វើចរាចរទំនិញនៅលើទីផ្សារហើយ ស្រាប់តែនៅថ្ងៃទី ១៥_១២_៩៧ ឈ្មោះ ម៉ូ ណាណា បានរៀបចំល្បិចបង្កើតក្រុមហ៊ុនមួយទៀត ដែលមានឈ្មោះហៅថា HEALTH BEAUTY ដើម្បីលួចនាំមុខទំនិញARNAUD ចូលមកលក់លើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ដោយផ្ទាល់ធ្វើឱ្យខ្លួនបាត់បង់នូវប្រយោជន៍ជាច្រើន ។

បានឃើញសាលក្រមលេខ៨២" ក " ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១_ ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ សេង ឃៀន ចុះថ្ងៃទី ០៣_៥_៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២_ ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និង ពាក្យសុំមេធាវី ចុះថ្ងៃទី ០២_៦_៩៨ របស់ឈ្មោះ ម៉ូ ណាណា ឱ្យមេធាវី សោម ច័ន្ទនីណា ដើម្បីធ្វើជាអ្នកតំណាងសិទ្ធិ និង ជាមេធាវីឱ្យខ្លួន ទៅតុលាការទុកជាត្រឹមត្រូវតាមទម្រង់និង គតិច្បាប់ ។

៣_ បង្គាប់ឱ្យឈ្មោះ ម៉ូ ណាណា ភេទប្រុស អាយុ ៤៦ឆ្នាំ ដែលមានលោក សោម ច័ន្ទនីណា ជាអ្នកតំណាងសិទ្ធិ និង ជាមេធាវី និង ក្រុមហ៊ុន STAR BEAUTY ដែលមានឈ្មោះ តុង ហ្វួត ជាប្រធានឱ្យគោរពកិច្ចសន្យា ចុះថ្ងៃទី០៦_៣_៩៧ រវាងក្រុមហ៊ុនSTAR BEAUTY និងហាងទឹកអប់៤០២JOLIE MADAME ដែលមានម្ចាស់ឈ្មោះ សេង ឃៀន ឡើងវិញ ។

៤_ បង្គាប់ឱ្យភាគីចុងចម្លើយឈ្មោះម៉ូ ណាណា ឈ្មោះតុង ហ្វួត ជាប្រធានក្រុមហ៊ុនSTAR BEAUTY សងការខាតបង់ជាប្រាក់ចំនួន ៣៣.០៣៣ ដុល្លារអាមេរិក " បីម៉ឺនបីពាន់សាមសិបបីដុល្លារអាមេរិក " ប្រាក់ជំងឺចិត្តចំនួន ៥.០០០ដុល្លារអាមេរិក " ប្រាំពាន់ដុល្លារអាមេរិក " ឱ្យទៅដើមចោទឈ្មោះ សេង ឃៀន ភេទប្រុស អាយុ ៣៩ឆ្នាំ ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។ ការទាមទារលើសពីនេះបដិសេធចោល ។ ក្នុងករណីឈ្មោះ ម៉ូ ណាណា និង ឈ្មោះ តុង ហ្វួត រឹងទទឹងមិនព្រមសងប្រាក់គ្រប់ចំនួនឱ្យទៅដើមចោទទេ សំរេចរឹបអូសលក់ឡាយឡុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន STAR BEAUTY និង ទ្រព្យសម្បត្តិរបស់ភាគីចុងចម្លើយឈ្មោះ ម៉ូ ណាណា ឈ្មោះតុង ហ្វួត ជាប្រធានក្រុមហ៊ុន STAR BEAUTY ដើម្បីធានាសំណង និង សំរេចដាក់ទុកបង្ខំរូបកាយលើឈ្មោះ ម៉ូ ណាណា កំណត់ ៨ខែ " ប្រាំបីខែ " តាមមាត្រា ១៣៣ នៃច្បាប់ស្តីពីវិធីអនុវត្តន៍សាលក្រមរដ្ឋប្បវេណី ។

៥_ បង្គាប់ឱ្យភាគីចុងចម្លើយឈ្មោះ ម៉ូ ណាណា និង ឈ្មោះ តុង ហ្វួត បង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីង ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីភាគហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០រៀល ប្រាក់នេះដើមចោទបានបង់រួចហើយ ។ កាលបើប្តូរសបណ្តឹងឧទ្ធរណ៍បង្គាប់ឱ្យភាគីចុងចម្លើយ

ឈ្មោះ អ៊ូ ណាណា និង ឈ្មោះ តុង ហួត សងប្រាក់ចំនួន ៧.០០០រៀលនេះ ទៅដើមចោទវិញ និង បង្គាប់ឱ្យបង់ពន្ធសមាមាត្រចំនួន ១ភាគរយ លើទឹកប្រាក់ទាំងអស់ ដែលចុងចម្លើយត្រូវសងឱ្យដើមចោទ ។

៦_ សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ ចំពោះមុខមេធាវីតំណាងសិទ្ធិរបស់ចុងចម្លើយ សំរេចបើកផ្លូវឧទ្ធរណ៍ ក្នុងកំណត់ច្បាប់គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៦២ " ក " ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៩៨ របស់លោក សោម ចំន្ទឌីណា ដែលប្តឹងជំទាស់នឹងសាលក្រមលេខ ៨២ " ក " ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញគ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៨៦ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលបណ្តឹងឧទ្ធរណ៍លេខ៦២ " ក " ចុះថ្ងៃទី ១២_៨_១៩៩៨ របស់លោកសោម ចំន្ទឌីណា មេធាវីផ្តល់ឱ្យភាគីចុងចម្លើយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយខុសនឹងគតិច្បាប់ ។

២_ តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៨២ " ក " ចុះថ្ងៃទី ២២_៧_១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣_ វិបរូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺៈ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីង២.៥០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៥០០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល ចំណាយលើអាជ្ញាធរតុលាការ ៥០០០រៀល សរុប១៣.០០០រៀល ។

៤_ សាលដីកានេះ ជំនុំជំរះនាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ចំពោះមុខគូក្តី និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៥៦ ចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ១៩៩៩ របស់លោក អ៊ូ ណាណា បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៨៦ ចុះថ្ងៃទី២៦ខែកុម្ភៈឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី ០៦_៦_៩៩ របស់ឈ្មោះ អ៊ូ ណាណា " តំណាងដោយលោក មេធាវី សោម ចំន្ទឌីណា " ។

បានឃើញសារណាតប ចុះថ្ងៃទី ២៦_៧_៩៩ របស់ឈ្មោះ សេង ឈៀន ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ :

- ក្រោយពីបានពិនិត្យ លើសាលដីការដ្ឋប្បវេណីលេខ៨៦ ចុះថ្ងៃទី ២៦_០២_៩៩ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ ។

- អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ ។

ក្រឡាបញ្ជីឡើងអានសារណារបស់ឈ្មោះ អ៊ូ ណាណា

បានស្តាប់ចម្លើយរបស់ឈ្មោះ សេង ឈៀន ជាដើមចោទនិងជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : មុនដំបូងខ្ញុំពុំបានដឹងថា ក្រុមហ៊ុន STAR BEAUTY នោះ មានអ្នកណាខ្លះ ហើយ

ក៏មិនដឹងអ្នកណាជាបណ្ណាធិការទី១ ទី២ ទី៣ ដែរ ព្រោះខ្លួនស្គាល់តែលោក ជូ ណាណា ម្នាក់ប៉ុណ្ណោះដែលជាអ្នកពិភាក្សាមុខទំនិញ អាណូត ផេះ តម្លៃថ្នាលរបស់ឈានដល់ការព្រមព្រៀងគ្នាធ្វើកិច្ចសន្យាចុះហត្ថលេខាជាមួយគ្នា ក្រោយមកគាត់បាននែណាំខ្លួនឱ្យស្គាល់ឈ្មោះតុង ហួត និងជា លីម ថា ជាម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនSTAR BEAUTY ដែរ ហើយគាត់ទៅស្រុកបារាំងទៅ ។ ទៅដល់បារាំងគាត់សរសេរសំបុត្រឱ្យខ្លួនជាបន្តបន្ទាប់ និង ទូរស័ព្ទមកខ្លួនថែមទៀត ដើម្បីឱ្យខ្លួនយល់ព្រមចុះហត្ថលេខាលើកិច្ចសន្យាជាមួយឈ្មោះតុង ហួត និងជា លីម ព្រោះគាត់ជាប់រវល់ ។ ហើយខ្លួនសូមបញ្ជាក់ថា ឈ្មោះ ជូ ណាណា មិនមែនជាសាក្សីទេ គឺជាបុគ្គលិកក្នុងភាគី " ក " ដែលមានភាគហ៊ុនក្នុងក្រុមហ៊ុន STAR BEAUTY ពិតប្រាកដ និងដែលជាអ្នកប្រព្រឹត្តខុសកិច្ចសន្យា ហើយឈ្មោះជូ ណាណា លួចបើកទំនិញដែលសមត្ថកិច្ចតុលាការកំពុងហាមឃាត់យកចេញ ទៅទួលក្នុងបន្ទាយឃាតាយុទ្ធភូមិភាគពិសេសនៅថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ ១៩៩៨ ទាំងថ្ងៃត្រង់ ។ ក្នុងរឿងនេះ ក៏មានសាក្សីដែលបាននាំទំនិញនោះមកឃាត់ទុកក្នុងតុលាការក្រុងភ្នំពេញ ហើយមានលោកព្រះរាជអាជ្ញា ឈិន ជីវ៉ា ជាអ្នកទទួលឃាត់ទំនិញដែលលោក ជូ ណាណា បានលួចដឹកចេញរំលោភលើដីកាសំរេចតាមពាក្យសុំរបស់តុលាការក្រុងភ្នំពេញ ។

<u>សំណូមពររបស់ខ្លួនគឺ</u> ៖

១- បដិសេធសារណារបស់លោក សោម ចំនួឌីណា មេធាវីតំណាងការពារឱ្យឈ្មោះ ជូ ណាណា ។

២- តំកល់សាលដីការបស់តុលាការសាលាឧទ្ធរណ៍

៣- ឃាត់ខ្លួនឬ ដកលិខិតឆ្លងដែនរបស់លោកជូ ណាណា និងលោកតុង ហួត ជាបណ្ដោះអាសន្ន ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោក មេធាវី សោម ចំនួឌីណា ការពារឱ្យចុងចម្លើយ និង ជាម្ចាស់បណ្ដឹងសាទុក្ខ នៅពេលសវនាការថា ៖ នៅថ្ងៃទី ២៥-០១-៩៧ ឈ្មោះ តុង ហួត , ជា លីម និង ជូ ណាណា បានចុះលក្ខន្តិកៈបង្កើតក្រុមហ៊ុនមួយឈ្មោះSTAR BEAUTY អាហរ៍ណ នីហរ៍ណ ដែលមានទីតាំងនៅផ្ទះលេខ ៨$E_1$ ផ្លូវកម្ពុជាក្រោម សង្កាត់ផ្សារថ្មីទី ២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ក្នុងនេះមានឈ្មោះ តុង ហួត ៤០ភាគហ៊ុន ទទួលងារជាបណ្ណាធិការក្រុមហ៊ុនឈ្មោះ ជា លីម មាន ៣០ភាគហ៊ុន ជាសមាជិកក្រុមហ៊ុន ជាសមាជិកក្រុមហ៊ុនឈ្មោះ ជូ ណាណា មាន៣០ភាគហ៊ុន ជាសមាជិកក្រុមហ៊ុន ។ នៅថ្ងៃទី០៦-៣-៩៧ ឈ្មោះ តុង ហួត ដែលជាបណ្ណាធិការក្រុមហ៊ុន បានចុះកិច្ចសន្យាជាមួយឈ្មោះ សេង យៀន ដែលជាប្រធានក្រុមហ៊ុនទឹកអប់ ៤០២ ស៊ូលីម៉ាដាម ដោយចុះកិច្ចសន្យាប្រគល់ទំនិញផ្ដាច់មុខម៉ាកចំនួន១២មុខ ទៅឈ្មោះ សេង យៀន និង ចុះកិច្ចសន្យាទទួលប្រាក់កក់ និង ធានាដោយមានឈ្មោះ ម៉ាន ហ៊ាន , ជា លីម , ជូ ណាណា ដឹងឮជាសាក្សី ។ ហើយហេតុផល និង សន្និដ្ឋាន មាន ៖

១- ក្នុងលក្ខន្តិកៈ ក្រុមហ៊ុន STAR BEAUTY មានឈ្មោះ តុង ហួត ជាបណ្ណាធិការ .

២- អំពីពាក្យបណ្ដឹងរបស់ឈ្មោះ សេង យៀន តាមកិច្ចសន្យាមិនអាចលើកយកមកដោះស្រាយបានទេ ព្រោះជាបណ្ដឹងខុសបុគ្គលដែលត្រូវទទួលខុសត្រូវ ។

៣- បើភាគីចុះកិច្ចសន្យាគឺជាឈ្មោះ តុង ហួត ហេតុអ្វីបានជាប្ដឹងពីឈ្មោះ ជូ ណាណា .

៤- រីឯឈ្មោះ ម៉ាន់ ហ៊ាន , ជា លីម , ជូ ណាណា គឺគ្រាន់តែជាសាក្សីដឹងឮ ចុះហេតុអ្វី - បានជាត្រូវទទួលខុសត្រូវសំណង ។

៥- ហេតុអ្វីបានជាឈ្មោះ សេង ឈៀន ព្រងើយកន្តើយនឹងឈ្មោះ ផូ ណាណា ។

<u>សំណូមពរ</u> :

ចាត់ទុកបណ្តឹងរបស់ឈ្មោះ សេង ឈៀន ចុះថ្ងៃទី ០៣-៥-៩៨ ទុកជាឥតបានការដោយខុសនឹងទំរង់ច្បាប់ ។

- សុំទាមទារឱ្យឈ្មោះ សេង ឈៀន បង់ជម្ងឺចិត្តដែលប៉ះពាល់ដល់កិត្តិយស ពេលវេលាសោហ៊ុយចំនួន ១០.០០០ដុល្លារអាមេរិក ដល់ឈ្មោះ ផូ ណាណា ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់លោក សោម ចំន្ទឹណា តំណាងឱ្យលោក ផូ ណាណា ចម្លើយរបស់លោក សេង ឈៀន និងសេចក្តីសន្និដ្ឋានរបស់មេធាវីខាងចម្លើយ.
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

# តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៨៦ ចុះថ្ងៃទី ២៩ ខែមិនា ឆ្នាំ១៩៩៩ របស់លោក ផូ ណាណា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់លោកផូ ណាណា ក្នុងសារណា ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៩៩ ថា : លោកគ្រាន់តែជាសាក្សីដឹងឮ ក្នុងកិច្ចសន្យា ចុះថ្ងៃទី ០៦-៣-៩៧ លក់ទំនិញផ្តាច់មុខរវាងក្រុមហ៊ុន ស្កាបីឃ្វីធី និងហាងទឹកអប់ ៤០២ ហ្សូលីម៉ាដាម តែប៉ុណ្ណោះ ដូច្នេះលោកពុំទទួលខុសត្រូវក្នុងការខាតបង់អ្វីទាំងអស់នោះ គឺជាការពុំត្រឹមត្រូវឡើយពីព្រោះថា :

+ លោក ផូ ណាណា ជាសមាជិកភាគហ៊ុនសកម្មម្នាក់បានដឹងច្បាស់ពីការងាររកស៊ីរបស់ក្រុមហ៊ុនខ្លួន លោកក៏បានទទួលស្គាល់ដែរថា លោកបានធ្វើសាក្សីដឹងឮក្នុងការលក់ទំនិញផ្តាច់មុខនេះ ម្យ៉ាងទៀតលោកបានធ្វើលិខិតប្រគល់សិទ្ធិចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ១៩៩៧ ប្រគល់សិទ្ធិលក់ផ្តាច់មុខនូវមុខទំនិញ ក្រែមអាណូត ឱ្យហាងទឹកអប់ ៤០២ ហ្សូលីម៉ាដាម កំណត់រយៈពេលមួយឆ្នាំ ហើយរយៈពេលនេះក៏ពុំទាន់ផុតកំណត់នៅឡើយ នេះជាការរំលោភលើកិច្ចសន្យាពិតប្រាកដ ។

+ ក្នុងពេល ដែលក្រុមហ៊ុនរបស់ខ្លួនកំពុងជាប់កិច្ចសន្យាជាមួយហាងទឹកអប់ ៤០២ ហ្សូលីម៉ាដាម លោក ផូ ណាណានិងលោកតុង ហ្វួត បានឃុបឃិតគ្នាបង្កើតក្រុមហ៊ុនហែលប៊ីឃ្វីធី ដែលមានលោកផូ ណាណា ជាបណ្ណាធិការទី១ លោក តុង ហ្វួត ជាបណ្ណាធិការទី២ ហើយលោកទាំងពីរក៏បាននាំទំនិញចំនួន ១២មុខ ម៉ាក្សអាណូតមកលក់ដូចគ្នានឹងហាងទឹកអប់ ៤០២ ហ្សូលីម៉ាដាម ពិតប្រាកដមែន ។

+ ផ្អែកតាមលិខិតបញ្ជាក់ជូនចំពោះតុលាការគ្រប់លំដាប់ថ្នាក់ ចុះថ្ងៃទី ២៤-០២-១៩៩៩ លោក តុង ហ្វួត បានទទួលស្គាល់ថា ខ្លួនលោក និង លោក ផូ ណាណា បានបើកក្រុមហ៊ុន ហែលប៊ីឃ្វីធី នឹងបាននាំទំនិញម៉ាក្សអាណូតពីប្រទេសបារាំង កាលពីថ្ងៃទី ២០-៤-៩៨ មករំលោភលើកិច្ចសន្យាចុះថ្ងៃទី ០៦-៣-៩៧ រវាងក្រុមហ៊ុនស្កាបីឃ្វីធី និងហាងទឹកអប់ ៤០២ ហ្សូលីម៉ាដាម ពិតប្រាកដមែន ។

- យល់ឃើញថា ការដែលមេធាវីលោក ផូ ណាណា លើកឡើងថា បណ្តឹងដើម របស់ដើមចោទពុំត្រឹម

ត្រូវនោះ ហើយកូនក្តីលោកពុំបាច់កាតព្វកិច្ច និងកិច្ចសន្យាចុះថ្ងៃទី ០៦_៣_៩៧ នោះជាការភាន់ច្រឡំ ពីព្រោះអ្នករំលោភកិច្ចសន្យា ចុះថ្ងៃទី ០៦_៣_៩៧ គឺលោក ដូ ណាណា និង លោក តុង ហួត ដែលបង្កើតក្រុមហ៊ុនថ្មីមួយទៀតគឺក្រុមហ៊ុន ហៃលបីឃ្មី ហើយនាំមុខទំនិញដែលមកលក់ដោយគ្មានការយល់ព្រមពីហាងទឹកអប់ ៤០២ ហ្សូលីម៉ាដាម ដូច្នេះការដែលតុលាការថ្នាក់ក្រោមសំរេចឱ្យលោកទាំងពីរនេះ រួមគ្នាសងនោះ ជាការត្រឹមត្រូវហើយ ។

- យល់ឃើញថា សាលដីការឧទ្ធរណ៍លេខ៨៦ ចុះថ្ងៃទី ២៦_០២_៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខ លោក សេង យៀន កំបាំងមុខលោក ដូ ណាណា ប៉ុន្តែចាត់ទុកជាចំពោះមុខ

១_ ទទួលបណ្តឹងសាទុក្ខលេខ ៩៦ ចុះថ្ងៃទី ២៩ ខែមិនា ឆ្នាំ១៩៩៩ របស់លោក ដូ ណាណា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២_ តម្កល់សាលដីការឧទ្ធរណ៍លេខ ៨៦ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣_ រឹបអូសប្រាក់ប្រដាប់ក្តី ដែលលោក ដូ ណាណា បានបង់រួចហើយ នៅតុលាការកំពូល ចំនួន ១៩.០០០រៀលគឺ ៖

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

បង្គាប់ឱ្យលោក ដូ ណាណា និង លោក តុង ហួត បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការក្រុងភ្នំពេញ ។

៥_ សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ១៩៩៩ ។